

# ការធ្វើតេស្តឥតគិតថ្លៃដ៏ងាយស្រួលអាច ជួយសង្គ្រោះជីវិតរបស់លោកអ្នក

មនុស្សខ្លះយល់ឃើញថា វាជាការពិបាកនឹងនិយាយអំពីជម្ងឺមហារីក - ការនេះរឹតតែពិបាកថែមទៀត ពេលណាវាជាជម្ងឺមហារីកពោះវៀន។ ក៏ប៉ុន្តែ ការនិយាយអំពីរឿងនេះជាមួយវេជ្ជបណ្ឌិត ក្រុមគ្រួសារ ជនជាទីស្រឡាញ់ និងមិត្តដ៏ទុកចិត្តរបស់លោកអ្នក អាចជួយសង្គ្រោះជីវិតរបស់លោកអ្នក។

ដំណឹងល្អគឺថា ប្រសិនបើគេរកឃើញវាបានទាន់ពេល ជម្ងឺមហារីកពោះវៀនអាចត្រូវគេព្យាបាល ដោយជោគជ័យ។ ដំណឹងល្អមួយទៀតគឺថា រដ្ឋាភិបាលអូស្ត្រាលីមានកម្មវិធីពិនិត្យមើលដោយឥត គិតថ្លៃ ដែលអាចធ្វើឲ្យលោកអ្នកបំពេញការធ្វើតេស្តជម្ងឺមហារីកពោះវៀនបានដោយខ្លួនឯង។

នៅក្នុងឆ្នាំដែលលោកអ្នកចូលអាយុ 50, 55, 60, 65, 70 ឬ 74 ឆ្នាំ រដ្ឋាភិបាលនឹងផ្ញើជូនលោកអ្នក តាមប្រៃសណីយ៍នូវគ្រឿងប្រដាប់សម្រាប់ធ្វើតេស្តពិនិត្យមើលដោយឥតគិតថ្លៃរបស់លោកអ្នក។ មានជំហានមួយចំនួននៅក្នុងដំណើរការធ្វើតេស្ត ក៏ប៉ុន្តែលោកអ្នកអាចបំពេញដំណាក់កាលដំបូងនៃការ ធ្វើតេស្ត ជាឯកជននៅតាមផ្ទះរបស់លោកអ្នក។

តើលោកអ្នកចង់ដឹងច្រើនថែមទៀតឬទេ
សូមបើកមើលវិបសាយ http://www.cancerscreening.gov.au/bowelcancer/khmer
ដើម្បីទទួលយកព័ត៌មានពិស្តារអំពីកម្មវិធីជាភាសារបស់លោកអ្នក។

ប្រសិនបើលោកអ្នកប្រាថ្នាចង់និយាយជាមួយអ្នកបកប្រែភាសា សូមទូរស័ព្ទលេខ 13 14 50 រួចស្នើសុំឲ្យគេទូរស័ព្ទទៅ ខ្សែទូរស័ព្ទផ្តល់ព័ត៌មានស្តីអំពីកម្មវិធីជាតិលើការពិនិត្យមើលជម្ងឺមហារីកពោះវៀន (National Bowel Cancer Screening Program) លេខ 1800 118 868។

Australian Government
Department of Health and Ageing

NATIONAL BOWEL CANCER
SCREENING PROGRAM